**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៥២/២១/២០១៣ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣

**ជម្រាបមក**

**លោក រស់ សួ**

ទីលំនៅបច្ចុប្បន្ន ភូមិ១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

**កម្មវត្ថុ :** សំណើសុំប្តឹងបដិសេធសេចក្តីសម្រេចលេខ ៧៥៨/១៣ គ.ជ.ប ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប ។

**យោង :**
- ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៥
- ពាក្យបណ្តឹងរបស់លោក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣
- លិខិតលេខ ៧៥៨/១៣ គ.ជ.ប ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកថា ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលពាក្យបណ្តឹងរបស់លោក និង បានដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ ពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣ រួចហើយ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា លិខិតលេខ ៧៥៨/១៣ គ.ជ.ប ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**
**ប្រធាន**

**ឯក សំអុល**